# អំពើដែលព្រះតថាគត មិនចាំបាច់រក្សា ឬរវាំង ៣

**តីណិ តថាគតស្ស អរក្ខេយ្យានិ** អំពើដែលព្រះតថាគត មិនចាំបាច់រក្សា ឬរវាំង មាន ៣ យ៉ាង គឺ៖

១. **បរិសុទ្ធកាយសមាចារោ អាវុសោ តថាគតោ នត្ថិ តថាគតស្ស កាយទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរោ អញ្ញាសីតិ** ម្នាលអាវុសោទាំង ឡាយ ព្រះតថាគតមានកាយសមាចារបរិសុទ្ធ ព្រះតថាគត គប្បីរក្សានូវកាយទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវកាយទុច្ចរិតរបស់អញនេះ កាយទុច្ចរិតនោះមិនមានដល់ព្រះតថាគតឡើយ

២. **បរិសុទ្ធវចីសមាចារោ អាវុសោ តថាគតោ នត្ថិ តថាគតស្ស វចីទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរោ អញ្ញាសីតិ** ម្នាល អាវុសោទាំងឡាយ ព្រះតថាគតមានវចីសមាចារបរិសុទ្ធ ព្រះតថាគតគប្បីរក្សានូវវចីទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវវចីទុច្ចរិតរបស់អញនេះ វចីទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ

៣. **បរិសុទ្ធមនោសមាចារោ អាវុសោ តថាគតោ នត្ថិ តថាគតស្ស មនោទុច្ចរិតំ យំ តថាគតោ រក្ខេយ្យ មា មេ ឥទំ បរោ អញ្ញាសីតិ** ម្នាលអាវុសោទាំង ឡាយ ព្រះតថាគតមានមនោសមាចារបរិសុទ្ធ ព្រះតថាគតគប្បីរក្សានូវមនោទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវមនោទុច្ចរិតរបស់អញនេះ មនោទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ

*( បិដកលេខ ១៩ ទំព័រ ១៣៨-៩ )*

អធិប្បាយ

ពាក្យថា **អរក្ខេយ្យានិ** ប្រែថា មិនចាំបាច់រក្សា ។ លោកសម្ដែងន័យថា មិនមានកិច្ចដែលនឹងចាំបាច់ត្រូវរក្សាទ្វារនីមួយៗ ក្នុងចំណោមទ្វារទាំង ៣, គ្រប់ទ្វារទាំងអស់រក្សាទុកល្អហើយដោយសតិតែម្យ៉ាង ។ ពាក្យថា **បដិច្ឆាទេមិ** សេចក្ដីថា កាយទុច្ចរិតនេះកើតឡើងព្រោះការមិនរវាំងរបស់តថាគត, តថាគតនឹងរក្សាមិនឲ្យអ្នកដទៃដឹង ។ ពាក្យថា **នត្ថិ តថាគតស្ស** សេចក្ដីថា កាយទុច្ចរិតដែលនឹងត្រូវរក្សាយ៉ាងនោះ មិនមានដល់ព្រះតថាគត ។ សូម្បីក្នុងចំណែកដ៏សេស [ គឺវចីទុច្ចរិតជាដើម ] ក៏មានន័យនេះដូចគ្នា ។

*សួរថា* ព្រះខីណាស្រព មានកាយសមាចារជាដើម មិនបរិសុទ្ធទេឬ?
*ឆ្លើយថា* មិន មែនមិនបរិសុទ្ធទេ តែថាបរិសុទ្ធមិនស្មើនឹងព្រះតថាគត ។ ព្រះខីណាស្រពដែលមានការសិក្សាមកតិច រមែងមិនត្រូវអាបត្តិដែលជាលោកវជ្ជៈ ក៏ពិតមែន, តែព្រោះមិនឈ្លាសក្នុងពុទ្ធប្បញ្ញត្តិ ក៏រមែងត្រូវអាបត្តិក្នុងកាយទ្វារ ដូចជាការធ្វើវិហារ ធ្វើកុដិ ( ហួសប្រមាណ ខុសនឹងពុទ្ធប្បញ្ញត្តិ ) រមែងនៅរួមដេករួម ( នឹងអនុបសម្បន្នជាដើម ) ។ រមែងត្រូវអាបត្តិក្នុងវចីទ្វារ ដូចជាការធ្វើជាមេអណ្តើក ពោលធម៌ដោយបទ សម្តែងធម៌ឲ្យលើសពី ៥-៦ មាត់ ( ដល់មាតុគ្រាម ) ពោលអួតឧត្តរិមនុស្សធម្មដែលមានពិត ( ជាដើម ) ។ រមែងត្រូវអាបត្តិព្រោះទទួលមាស និងប្រាក់ តាមមនោទ្វារដោយអំណាចសេចក្តីត្រេកអរក្នុងមាស និងប្រាក់ដែលគេរក្សាទុកដើម្បីខ្លួន ។ សូម្បីព្រះខីណាស្រព ប្រហែលព្រះធម្មសេនាបតីសារីបុត្តក៏នៅកើតមនោទុច្ចរិតឡើងបាន ដោយអំណាចការត្រិះរិះក្នុងមនោទ្វារ ។

កាល សាក្យបាតុមេយ្យកៈ សូមខមាទោសព្រះមានព្រះភាគដើម្បីប្រយោជន៍ដល់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ក្នុងគ្រាដែលទ្រង់បណ្តេញព្រះថេរៈទាំងពីររូបនោះព្រមទាំងភិក្ខុ ប្រមាណ ៥០០ រូប ក្នុងរឿងបាតុមៈ ព្រះថេរៈ ដែលព្រះដ៏មានព្រះភាគត្រាស់សួរថា "ម្នាលសារីបុត្ត តើអ្នកគិតដូចម្តេច កាលភិក្ខុសង្ឃត្រូវតថាគតបណ្តេញហើយ" ។ ដូច្នេះ ក៏កើតគំនិតនេះឡើងមកថា "អញត្រូវព្រះសាស្តាបណ្តេញ ព្រោះមិនឈ្លាសក្នុងរឿងបរិស័ទ, ចាប់តាំងពីឥឡូវនេះទៅ អញនឹងមិនប្រៀនប្រដៅជនដទៃទៀតទេ" ទើបបានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា "ភិក្ខុសង្ឃដែលព្រះដ៏មានព្រះភាគបណ្តេញហើយ, ឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ខ្វល់ខ្វាយតិច ប្រកបទិដ្ឋធម្មសុខវិហារ, សូម្បីពួកយើងទាំងពីររូបក៏នឹងខ្វល់ខ្វាយតិច ប្រកបទិដ្ឋធម្មសុខវិហារដែរ" ។ លំដាប់នោះ ព្រះសាស្តាការនឹងទ្រង់លើកយកកិច្ចដែលគួរតិះដៀល ព្រោះមនោទុច្ចរិតនោះ របស់ព្រះថេរៈ ទើបត្រាស់ថា "កុំឡើយសារីបុត្រ ការគិតយ៉ាងនេះមិនគួរកើតឡើងដល់អ្នកទៀតឡើយ" ។ សូម្បីគ្រាន់តែគំនិតថា "យើងនឹងមិនបង្រៀនជនដទៃ យ៉ាងនេះ" ក៏ឈ្មោះថា ជាមនោទុច្ចរិតរបស់ព្រះថេរៈ តែព្រះដ៏មានព្រះភាគ រមែងមិនមានព្រះតម្រិះនោះ ហើយការដែលព្រះដ៏មានព្រះភាគទ្រង់ដល់នូវសព្វញ្ញុតញ្ញាណហើយ នឹងមិនគប្បីមានទុច្ចរិតនោះ មិនមែនជាហេតុគួរឲ្យអស្ចារ្យទេ សូម្បីតែស្ថិតនៅក្នុងភូមិនៃព្រះ

ពោធិសត្វ ទ្រង់ប្រកបសេចក្ដីព្យាយាមអស់ ៦ ឆ្នាំ ព្រះអង្គក៏មិនមានទុច្ចរិតឡើយ ។ សូម្បីកាលពួកទេវតាកើតមានសេចក្ដីសង្ស័យយ៉ាងនេះថា "ស្បែកពោះជាប់នឹងឆ្អឹងខ្នង ( យ៉ាងនេះ ) ព្រះសមណគោតម ដល់នូវការរលត់សូន្យ ( ហើយទេដឹង )" កាលត្រូវមារមានចិត្តបាប ពោលថា "សិទ្ធត្ថ លោកត្រូវមកលំបាកលំបិនធ្វើអី លោកអាចសោយភោគសម្បត្តិបានផង ធ្វើបុណ្យបានផង" ដូច្នេះ សូម្បីតែគំនិតថា "អញនឹង ( ត្រឡប់ទៅ ) សោយភោគសម្បត្តិ" ក៏មិនបានកើតឡើងឡើយ ។ ក្រោយមក មារក៏ជាប់តាមព្រះមានព្រះភាគកាលដែលនៅជាព្រះពោធិសត្វ អស់រយៈពេល ៦ ឆ្នាំ ក្នុងវេលាដែលបានត្រាស់ដឹងជាព្រះពុទ្ធហើយមួយឆ្នាំទៀត ក៏មិនបានឃើញទោសណានីមួយឡើយ ទើបពោលសេចក្ដីនេះទុកហើយទើបចៀសចេញ ថា៖

**សត្តវស្សានិ ភគវន្តំ អនុពន្ធិំ បទាបទំ**
**ឱតារំ នាធិគច្ឆិស្សំ សម្ពុទ្ធស្ស សតីមតោ ។**

"យើង ជាប់តាមព្រះមានព្រះភាគគ្រប់ជំហាន អស់រយៈកាល ៧ ឆ្នាំ ក៏មិនបានឃើញទោសណានីមួយ របស់ព្រះសម្មាសម្ពុទ្ធ ជាអ្នកមានសតិបរិបូណ៌ឡើយ" ។

ពុទ្ធធម៌ ១៨ ប្រការ
ប្រការមួយទៀត គប្បីជ្រាបការមិនមានទុច្ចរិតរបស់ព្រះមានព្រះភាគ ដោយអំណាចនៃពុទ្ធធម៌ ១៨ ប្រការ ។

**អដ្ឋារស ពុទ្ធធម្មា នាម នត្ថិ តថាគតស្ស កាយទុច្ចរិតំ, នត្ថិ វចីទុច្ចរិតំ, នត្ថិ មនោទុច្ចរិតំ, អតីតេ ពុទ្ធស្ស អប្បដិហតញាណំ, អនាគតេ, បច្ចុប្បន្នេ ពុទ្ធស្ស អប្បដិហតញាណំ, សព្វំ កាយកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ, សព្វំ វចីកម្មំ, សព្វំ មនោកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តិ, នត្ថិ ឆន្ទស្ស ហានិ, នត្ថិ វីរិយស្ស ហានិ, នត្ថិ សតិយា ហានិ, នត្ថិ ទវា, នត្ថិ រវា, នត្ថិ ចលិតំ នត្ថិ សហសា, នត្ថិ អព្យាវដោ មនោ, នត្ថិ អកុសលចិត្តន្តិ ។**

ពុទ្ធធម៌ ១៨ ប្រការទាំងនោះ គឺ ព្រះតថាគតមិនមានកាយទុច្ចរិត ១ មិនមានវចីទុច្ចរិត ១ មិនមានមនោទុច្ចរិត ១ ពុទ្ធញាណមិនមានអ្វីមករារាំងក្នុងអតីត ១ ពុទ្ធញាណមិនមានអ្វីមករារាំងក្នុងអនាគត ១ ពុទ្ធញាណមិនមានអ្វីមករារាំងក្នុង

បច្ចុប្បន្ន ១ កាយកម្មទាំងពួងរបស់ព្រះមានព្រះភាគ ស្របតាមពុទ្ធញាណ ១ វចីកម្មទាំងពួងរបស់ព្រះមានព្រះភាគ ស្របតាមពុទ្ធញាណ ១ មនោកម្មទាំងពួងរបស់ព្រះមានព្រះភាគ ស្របតាមពុទ្ធញាណ ១ មិនសាបសូន្យនូវឆន្ទៈ ១ មិនសាបសូន្យសេចក្តីព្យាយាម ១ មិនបាត់បង់សតិស្មារតី ១ មិនលេងសើច ១ មិនរត់ ១ មិនភ្លាំងភ្លាត់ ១ មិនប្រញាប់ប្រញាល់ ១ មិនមានព្រះហឫទ័យដែលមិនខ្វល់ខ្វាយ ១ មិនមានអកុសលចិត្ត ១ ។

សូមអស់លោកអ្នកអនុមោទនា !

ចប់